# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៧. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមការងារសម្រាប់អនុវត្តគម្រោងស្តារជួសជុល ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយគម្រោងថវិកាកម្ចីធនាគារអភិវឌ្ឍន៍អាស៊ី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតរាជាយស្ម័យយានកម្ពុជា ជាសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៧២ អនក្រ.តត ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគម្រោងផ្លូវដែកសិង្ហបុរី-គុនមិញ
- យោងតាមអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងធនា[illegible] (ADB) ស្តីពីគម្រោងស្តារជួសជុលឡើងវិញផ្លូវដែកនៅកម្ពុជា ដែលបានចុះហត្ថលេខានៅថ្ងៃទី[illegible] ឆ្នាំ២០០៦

## ស ម្រ េ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតក្រុមការងារសម្រាប់អនុវត្តគម្រោងកំណែទម្រង់វចនាសម្ពន្ធ័គ្រប់គ្រងរាជាយស្ម័យយានកម្ពុជា និង គម្រោងស្តារជួសជុលហេដ្ឋារចនាសម្ពន្ធ័ផ្លូវដែក ដោយឥណទានថវិកាកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

## ជំពូកទី ២
## សមាសភាព

**មាត្រា ២.-**

គណៈកម្មាធិការតម្រង់ទិស ត្រូវបានយកពីសមាសភាព ក្នុងមាត្រា ២ ជំពូកទី ១ នៃអនុក្រឹត្យលេខ ២៧២ អនក្រ.តត ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគម្រោងផ្លូវដែកសិង្ហបូរី គុនមិញ ។

**មាត្រា ៣.-**

ក្រុមប្រឹក្សាគ្រប់គ្រងសម្បទាន ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម អ៊ុក ចាន់ | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- | ឯកឧត្តម សុខុម គគទន្តមុនី | ប្រធានអគ្គនាយក រាជាយស្ម័យយានកម្ពុជា | អនុប្រធាន |
| ៣- | ឯកឧត្តម ស៊ុយ សាន | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៤- | តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| ៥- | តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៦- | លោក រិត ចឿន | នាយកអាជីវកម្ម និងដឹកជញ្ជូនសមាជិក រាជាយស្ម័យយានកម្ពុជា | សមាជិក |
| ៧- | លោក ហ៊ុយ រិទ្ធ | នាយកក្បាលម៉ាស៊ីន និងទូរថភ្លើង រាជាយស្ម័យយានកម្ពុជា | សមាជិក |
| ៨- | លោក សុខ ណារី | នាយករងអាជីវកម្ម និងដឹកជញ្ជូន រាជាយស្ម័យយានកម្ពុជា | សមាជិក |
| ៩- | លោក ញ៉ឹក ធីរទុឡ្សន៍ | នាយករងរដ្ឋបាល រាជាយស្ម័យយានកម្ពុជា | សមាជិក |

មាត្រា ៤.-

ក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តគម្រោងស្តារជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជាដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោក យិត ប៊ុណ្ណា | នាយកមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស | នាយកគម្រោង |
| ២- លោក លី ម៉ូរិន | នាយកផ្លូវ ស្ពាន អាគារ រាជាយស្វ័យយានកម្ពុជា | ប្រធានគ្រប់គ្រងបច្ចេកទេស |
| ៣- លោក ចាន់ សំឡេង | នាយករងផ្លូវ ស្ពាន អាគារ រាជាយស្វ័យយានកម្ពុជា | ប្រធានគ្រប់គ្រងទូទៅ |
| ៤- លោក ខ្សែ ប៊ុនតឹក | ប្រធានបណ្តាញផ្លូវដែកពាយ័ព្យទិស រាជាយស្វ័យយានកម្ពុជា | ទទួលបន្ទុកបណ្តាញផ្លូវដែក (ភ្នំពេញ ប៉ោយប៉ែត) |
| ៥- លោក ម៉េង លី | ប្រធានបណ្តាញសិល្បៈការ្យ និងការងារថ្មី រាជាយស្វ័យយានកម្ពុជា | ទទួលបន្ទុកបណ្តាញផ្លូវដែក (ភ្នំពេញ ក្រុងព្រះសីហនុ) |
| ៦- លោក អ៊ិត ស៊ាងសុផល | មន្ត្រីនៃមជ្ឈមណ្ឌលស្រាវជ្រាវ ក្រសួងសាធារណការ និងដឹកជញ្ជូន | ទទួលបន្ទុកលទ្ធកម្ម គណនេយ្យ |
| ៧- លោក នឹង ម៉ារីណា | មន្ត្រីនៃមជ្ឈមណ្ឌលស្រាវជ្រាវ ក្រសួងសាធារណការ និងដឹកជញ្ជូន | ទទួលបន្ទុករដ្ឋបាល |
| ៨- លោក រតន៍ សាម៊ីន | មន្ត្រីខុទ្ទកាល័យ ក្រសួងសាធារណការ និងដឹកជញ្ជូន | ជំនួយការរដ្ឋបាល |

មាត្រា ៥.-

ក្រុមការងារសម្រាប់អភិវឌ្ឍន៍ដីធ្លី ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- លោក ស៊ូ ផល្លី | នាយករងរដ្ឋបាល រាជាយស្វ័យយានកម្ពុជា | ប្រធាន |
| ២- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| ៣- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | | សមាជិក |
| ៤- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | |
| ៥- តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | | |
| ៦- លោក នៅ ឌីណា | រាជាយស្វ័យយានកម្ពុជា | |

## ជំពូកទី ៣
## តួនាទី និងភារកិច្ច

**មាត្រា ៦..**

គណៈកម្មាធិការតម្រង់ទិស មានភារកិច្ចពិនិត្យ សម្របសម្រួល ផ្ដល់អនុសាសន៍ និងធ្វើសេចក្ដីសម្រេច លើការអនុវត្តគម្រោង។

**មាត្រា ៧..**

អង្គភាពគ្រប់គ្រងសម្បទាន មានភារកិច្ចរៀបចំ ពិនិត្យ និងវាយតម្លៃលើឯកសារលទ្ធកម្ម ដើម្បីផ្ដល់ សម្បទានដល់ប្រតិបត្តិករ ដែលជាក្រុមហ៊ុនឯកជនធ្វើអាជីវកម្មតាមផ្លូវដែកកម្ពុជា និងធ្វើការតាមដានត្រួតពិនិត្យ ផ្ដល់ របាយការណ៍លើការអនុវត្តកិច្ចសន្យាសម្បទានដល់ប្រតិបត្តិករ ដើម្បីរាយការណ៍ និងដាក់ជូនគណៈកម្មាធិការតម្រង់ទិស ពិនិត្យ និងសម្រេច។

**មាត្រា ៨..**

ក្រុមការងារសម្រាប់អនុវត្តគម្រោង ទទួលខុសត្រូវលើការអនុវត្ត និងគ្រប់គ្រងគម្រោងស្ដារជួសជុល សាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក រាប់បញ្ចូលទាំងលទ្ធកម្មសាងសង់ និងការដកប្រាក់កម្ចី។

**មាត្រា ៩..**

ក្រុមការងារសម្រាប់អភិវឌ្ឍន៍ដីធ្លី មានភារកិច្ចធ្វើការអភិវឌ្ឍដីធ្លីជាអចលនទ្រព្យរបស់រាជាយស្ម័យយាន កម្ពុជា ហើយស្ថិតក្រោមការគ្រប់គ្រងរបស់សហគ្រាសសាធារណៈ រាជាយស្ម័យយានកម្ពុជា។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ១០..**

គណៈកម្មាធិការតម្រង់ទិស ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ក្នុងការទំនាក់ទំនងការងាររបស់ខ្លួន។

**មាត្រា ១១..**

អង្គភាពគ្រប់គ្រងសម្បទាន និងក្រុមការងារបច្ចេកទេសអនុវត្តគម្រោង ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ត្រាជាផ្លូវការរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងការទំនាក់ទំនងការងាររបស់ខ្លួន។

មាត្រា ១២.-

ក្រុមការងារសម្រាប់អភិវឌ្ឍន៍ដីធ្លី ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់រាជាយស្ម័យយានកម្ពុជា។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

មាត្រា ១៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ